### ៥.សកម្មភាពផ្ដល់ដំបូន្មានអំពីបច្ចេកទេសកសិកម្ម និងការរស់នៅប្រចាំថ្ងៃ៖

គឺជាសកម្មភាព ដែលសហគមន៍កសិកម្មផ្ដល់ការបណ្ដុះបណ្ដាលឬដំបូន្មានអំពីបច្ចេកទេសកសិកម្ម និងសកម្មភាពរស់នៅប្រចាំថ្ងៃដល់សមាជិក។ សកម្មភាពនេះអាចលើកកម្ពស់គុណភាពកសិផលឬសេវាកម្មគាំទ្រដល់ផលិតកម្មកសិកម្ម។

ឧទាហរណ៍៖ សហគមន៍កសិកម្មមានផ្ដល់សេវាកម្មបណ្ដុះបណ្ដាលអំពីបច្ចេកទេសចិញ្ចឹមជ្រូក ទៅដល់សមាជិកដើម្បីឱ្យកសិករអាចចិញ្ចឹមជ្រូកឆាប់ធំ និងកាត់បន្ថយអត្រាងាប់នៃជ្រូក។

### ៦.បង្កើតមូលនិធិសង្គម៖

គឺជាមូលនិធិសម្រាប់ចូលរួមក្នុងសកម្មភាពសង្គម។

ឧទាហរណ៍៖ សហគមន៍កសិកម្មបង្កើតមូលនិធីសង្គ្រោះបន្ទាន់ សម្រាប់ជួយដល់សមាជិកដែលជួបបញ្ហាភ្លាមៗដូចជាគ្រោះថ្នាក់ចរាចរណ៍ ឬជម្ងឺ។

## សហគមន៍កសិកម្មមានរចនាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម ÷

១. **មហាសន្និបាត៖** គឺជាអង្គការខ្ពស់បំផុតរបស់សហគមន៍កសិកម្ម។ សមាជិកទាំងអស់ត្រូវចូលរួមក្នុងមហាសន្និបាតដើម្បីពិភាក្សា និងអនុម័តរាល់កិច្ចការរបស់សហគមន៍កសិកម្ម ព្រមទាំងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ។

២. **ក្រុមប្រឹក្សាភិបាល៖** គឺជាអ្នកដឹកនាំ និងអនុវត្តរាល់ដំណើរការរបស់សហគមន៍កសិកម្ម។

៣. **គណៈកម្មាធិការត្រួតពិនិត្យ៖** គឺជាអ្នកត្រួតពិនិត្យផ្ទៃក្នុងជាប្រចាំរបស់សហគមន៍កសិកម្ម។

៤. **នាយកប្រតិបត្តិ និងបុគ្គលិក៖** គឺជាបុគ្គលិកជំនាញដែលជួលដោយសហគមន៍កសិកម្ម និងជ្រើសរើសដោយក្រុមប្រឹក្សាភិបាល។

## រចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍កសិកម្ម




# គោលគំនិតសហគមន៍កសិកម្ម

2012 International Year of Co-operatives

ខិត្តប័ណ្ណនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយ គោលគំនិតសហគមន៍កសិកម្មដល់មន្ត្រីរាជរដ្ឋាភិបាល មន្ត្រី និងបុគ្គលិកសហគមន៍កសិកម្ម ប្រជាកសិករជាសមាជិក និងមិនមែនសមាជិកសហគមន៍កសិកម្ម និងបុគ្គលិកអង្គការ សំដៅចូលរួមអភិវឌ្ឍសហគមន៍កសិកម្ម និងសេដ្ឋកិច្ចជាតិ។

**ឆ្នាំ២០១៥**

**រៀបចំដោយ :គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC) នៃនាយកដ្ឋានសហគមន៍កសិកម្ម**

អាសយដ្ឋាន៖ លេខ៥៤បេ/៤៩អេហ្វ ផ្លូវ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ(០២៣) ៨៨៣ ៤២៧ ទូរសារលេខ(០២៣) ៨៨៣ ៤២៧

កាលពីឆ្នាំ២០០៣ សហគមន៍កសិកម្មដំបូងបានបង្កើតឡើងក្នុងខេត្តសៀមរាប ដោយផ្អែកទៅតាមព្រះរាជក្រឹត្យស្ដីពីការបង្កើត និងការប្រព្រឹត្តទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្ម សហភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និងបុរេសហគមន៍អភិវឌ្ឍន៍កសិកម្ម។ រហូតមកដល់ពាក់កណ្ដាលឆ្នាំ២០១៥ សហគមន៍កសិកម្មទាំងអស់នៅទូទាំងប្រទេស មានចំនួនជាង៦០០ បានរៀបចំបង្កើតឡើង ដោយប្រជាកសិករនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងកំពុងដំណើរការមុខរបររបស់ខ្លួន។

## តើសហគមន៍កសិកម្មជាអ្វី?

សហគមន៍កសិកម្មគឺ ជាអង្គការឯកជនមួយដែលបង្កើតឡើង ដោយកសិករមួយក្រុមតាមការស្ម័គ្រចិត្ត រួមគ្នាបង្កើតដើមទុន រួមគ្នាធ្វើម្ចាស់ និងរួមគ្នាគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យ សំដៅលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សមាជិក ដោយអនុលោមតាមគោលការណ៍គ្រឹះទាំងប្រាំពីរ របស់សម្ព័ន្ធសហគមន៍អន្តរជាតិ និងច្បាប់ស្ដីពីសហគមន៍កសិកម្មកម្ពុជា។

## តើអ្វីជាទិសដៅរបស់សហគមន៍កសិកម្ម?

ទិសដៅរបស់សហគមន៍កសិកម្មគឺ៖

- លើកកម្ពស់សេដ្ឋកិច្ចរបស់សមាជិក៖ ធ្វើឱ្យសមាជិកមានជីវភាពធូរធា តាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារពីអាជីវកម្មកសិកម្ម
- លើកកម្ពស់សង្គម៖ បង្កើនសាមគ្គីភាព ធានានូវសមភាព សមធម៌ និងការជួយគ្នាទៅវិញទៅមកក្នុងសហគមន៍កសិកម្ម ព្រមទាំងចូលរួមក្នុងការអភិវឌ្ឍន៍សង្គម។
- លើកកម្ពស់វប្បធម៌៖ ចូលរួមគាំទ្រដល់កិច្ចការវប្បធម៌ដូចជាការថែរក្សាប្រពៃណីរបស់ប្រជាកសិករ។

## ដើម្បីសម្រេចទិសដៅខាងលើសហគមន៍កសិកម្មគួរអនុវត្តន៍មុខរបរ និងសកម្មភាពដូចខាងក្រោម÷

### ១.មុខរបរឥណទានសហគមន៍កសិកម្ម៖

គឺជាមុខរបរដែលសហគមន៍កសិកម្ម ទទួលប្រាក់បញ្ញើសន្សំពីសមាជិកដោយផ្ដល់អត្រាការប្រាក់ ស្មើឬខ្ពស់ជាងក្រុមហ៊ុនឯកជន និងផ្ដល់ប្រាក់កម្ចីទៅដល់សមាជិកជាមួយអត្រាការប្រាក់ទាបជាង ឬស្មើក្រុមហ៊ុនឯកជន។

### ២.មុខរបរទីផ្សារ៖

គឺជាមុខរបរ ដែលសហគមន៍កសិកម្មប្រមូលទិញកសិផល ឬផលិតផលផ្សេងៗពីសមាជិក រួចលក់បន្តទៅដល់រោងចក្រ អ្នកនាំចេញឬទៅដល់អ្នកប្រើប្រាស់ផ្ទាល់។ មុខរបរនេះអាចឱ្យកសិករស្វែងរកបានទីផ្សារ និងមានអំណាចក្នុងការចរចារអំពីតម្លៃដើម្បីលក់ផលិតផលនានាបានតម្លៃខ្ពស់។

ឧទាហរណ៍៖ សហគមន៍កសិកម្មប្រមូលទិញស្រូវផ្ការំដួលពីសមាជិកបានចំនួន១០០តោន រួចលក់ទៅឱ្យអ្នកនាំស្រូវទៅលក់នៅបរទេសដោយផ្ទាល់បានតម្លៃមួយខ្ពស់ជាងកសិករម្នាក់ៗលក់ទៅឱ្យឈ្មួញកណ្ដាល។

### ៣.មុខរបរផ្គត់ផ្គង់៖

គឺជាមុខរបរ ដែលសហគមន៍កសិកម្មទិញទំនិញផ្សេងៗដូចជា ជីកសិកម្ម ថ្នាំកសិកម្ម ប្រេងម៉ាស៊ូត ដើម្បីលក់បន្តទៅដល់សមាជិក។ មុខរបរនេះធ្វើឱ្យកសិករមានអំណាច ក្នុងការចរចារទិញផលិតផលនានាប្រកបដោយគុណភាពក្នុងតម្លៃសមរម្យ និងឈានទៅដល់ការកាត់បន្ថយតម្លៃផលិតកម្មកសិកម្ម។

ឧទាហរណ៍៖ សហគមន៍កសិកម្មបានទិញជីកសិកម្មដុំចំនួនម្ភៃ(២០)តោន យកមកលក់រាយជូនសមាជិកក្នុងតម្លៃទាបជាងអ្នកលក់រាយនៅក្នុងតំបន់។

### ៤.មុខរបរប្រើប្រាស់រួមគ្នា៖

គឺជាមុខរបរដែល សហគមន៍កសិកម្មទិញឧបករណ៍កសិកម្ម គ្រឿងចក្រកសិកម្ម ឬសាងសង់ឃ្លាំងដើម្បីជួល ឬផ្ដល់សេវាកម្មដល់សមាជិក។ មុខរបរនេះអាចផលិតផលិតផល ឬផ្ដល់សេវាកម្មនានាដែលកសិករម្នាក់ៗ មិនអាចធ្វើបាន។

ឧទាហរណ៍៖ សហគមន៍កសិកម្មទិញម៉ាស៊ីនច្រូតស្រូវដើម្បីផ្ដល់សេវាកម្មគាំទ្រ ដល់ការងារប្រមូលផលស្រូវរបស់សមាជិក ដែលមិនមានលទ្ធភាពទិញយកមកប្រើប្រាស់ដោយខ្លួនឯង ដោយយកប្រាក់ឈ្នួលទាបជាងក្រុមហ៊ុនឯកជន។